ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌលេខ ៨៥ "ស"
ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៩២
ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥
សំណុំរឿងស៊ើបសួរលេខ ៤៧០៤
ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨
សំណុំរឿងជំនុំជម្រះលេខ ២៩៩៥
ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៨ ព្រឹក នៅសាលសវនាការទី៤ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៩២ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ចាន់នី ភេទប្រុស អាយុ ៥៨ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម អាសយដ្ឋានស្នាក់នៅផ្ទះសំណាក់ [redacted] ពេជ្រ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ស្រីពៅ មានកូន ៣ នាក់ ឪពុកឈ្មោះ [redacted] ស្បាង "ស" ម្តាយឈ្មោះ [redacted] ហ៊ាង "ស" ទោសពីមុន គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៣៦ "ខ១" ដ.ឃ.ដ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩។

ជាប់ចោទពីបទ របោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ និងពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣២៥៦ "ខ១" ដ.ដ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

២-ឈ្មោះ [redacted] ណារិទ្ធ ហៅ គោរព ភេទប្រុស អាយុ ៦១ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅសង្ក[redacted]

រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] សុធារី មានកូន ៣ នាក់ ឪពុកឈ្មោះ [redacted] យូសេង "ស" ម្តាយឈ្មោះ [redacted] វួច "ស" ទោសពីមុន គ្មាន

-នៅក្រៅឃុំ។

-មេធាវីការពារក្តីលោកមេធាវី [redacted] និងលោកមេធាវី [redacted] មុន្នី។

៣-ឈ្មោះ [redacted] YOUNG ភេទប្រុស អាយុ ៥០ ឆ្នាំ ជនជាតិវៀតណាម អាសយដ្ឋានស្នាក់នៅផ្ទះ [redacted] រាជធានីភ្នំពេញ។

-រត់គេចខ្លួន។

ជាប់ចោទពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣២៥៦ "ខ១" ដ.ដ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ANH DUNG ភេទប្រុស អាយុ ៥៤ ឆ្នាំ ជនជាតិវៀតណាម អាសយដ្ឋាននៅក្រុងChau Doc ខេត្តAn Giang ប្រទេសវៀតណាម។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីដើមឆ្នាំ២០១០ ឈ្មោះ [redacted] ចាន់នី បានលួងលោមឱ្យឈ្មោះ [redacted] ណារិទ្ធ បង្កើតក្រុមហ៊ុនមាននាមករណ៍ [redacted] ណារិទ្ធ អេក្រូត៍ខលឈើវឺឡុបមែន មានភាគហ៊ុន ៥០% ម្នាក់ ដោយឈ្មោះ [redacted] ចាន់នី មានតួនាទីជាប្រធានទីផ្សារ និងឈ្មោះ [redacted] ណារិទ្ធ ជាប្រធានក្រុមហ៊ុន។

តាមរយៈក្រុមហ៊ុននេះឈ្មោះ [redacted] ចាន់នី បានឱ្យបក្ខពួករបស់ខ្លួនឈ្មោះ [redacted] YOUNG ជាជនជាតិវៀតណាម ធ្វើសកម្មភាពបញ្ចុះបញ្ចូលជនរងគ្រោះឈ្មោះ [redacted] ANH DUNG ជាជនជាតិវៀតណាម ឱ្យទម្លាក់ប្រាក់ឱ្យពួកគេយកទៅរៀបចំដេញថ្លៃដីព្រៃសម្បទាន និងប្រមូលផលព្រៃឈើលក់ឱ្យទៅឈ្មោះ [redacted] ANH DUNG តាមរយៈសកម្មភាពនេះឈ្មោះ [redacted] ចាន់នី និងឈ្មោះ [redacted] YOUNG បានទទួលប្រាក់ពីឈ្មោះ [redacted] ANH DUNG ជាបន្តបន្ទាប់សរុបចំនួន ២៥០.០០០ (ពីរសែនប្រាំម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែក្នុងអំឡុងពេលនោះឈ្មោះ [redacted] ចាន់នី និងឈ្មោះ [redacted] YOUNG ពុំបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ ឈ្មោះ [redacted] ចាន់នី បានប្រគល់មូលប្បទានបត្រគ្មានសាច់ប្រាក់ឱ្យទៅឈ្មោះ [redacted] ANH DUNG តាមរយៈមូលប្បទានបត្រលេខ ០៥៩១២២ របស់ធនាគារ វឌ្ឍនៈ មានទឹកប្រាក់ចំនួន ៣.៣០០.០០០ (បីលាន បីសែន) ដុល្លារអាមេរិក ដោយឡែកចំពោះឈ្មោះ [redacted] ណារិទ្ធ ពុំបានចូលរួមធ្វើសកម្មភាពជាមួយឈ្មោះ [redacted] ចាន់នី និងឈ្មោះ [redacted] YOUNG ទេ។

-បានឃើញ របាយការណ៍លេខ ០៥៨ សណ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ របស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៦០៨ អ.យ.ច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

Scanned with CamScanner

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣២៦៥ “ខ១” ដ.ង ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## <u>នារពេលសចនាគារ</u>

-ជនជាប់ចោទឈ្មោះ [redacted] ចាន់នី បានឆ្លើយថា ខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន ខ្លួននិងឈ្មោះ [redacted] ណារិទ្ធ បានបើកក្រុមហ៊ុន [redacted] ណារិទ្ធ គោលបំណងដើម្បីធ្វើសកម្មភាពចូលដេញថ្លៃព្រៃសម្បទាន បន្ទាប់មកខ្លួននិងឈ្មោះ [redacted] YOUNG បានទំនាក់ទំនងជាមួយឈ្មោះ [redacted] ANH DUNG ដើម្បីឱ្យឈ្មោះ [redacted] ANH DUNG ទម្លាក់ប្រាក់ឱ្យដើម្បីយកប្រាក់នោះទៅចំណាយសិក្សាដីព្រៃ និងដើម្បីប្រមូលឈើលក់ឱ្យឈ្មោះ [redacted] ANH DUNG វិញ ហើយខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] ANH DUNG ផ្ទាល់ខ្លះនិងខ្លះទៀតទទួលយកបន្តពីឈ្មោះ [redacted] YOUNG ដែលមានចំនួនសរុបត្រឹមតែ ១០០.០០០ (មួយសែន) ដុល្លារអាមេរិក ប៉ុណ្ណោះ។

ចំពោះឈ្មោះ [redacted] ណារិទ្ធ គាត់ពុំបានធ្វើសកម្មភាពនេះជាមួយពួកខ្លួនទេ បន្ទាប់មកខ្លួនមិនអាចអនុវត្តកាតព្វកិច្ចបាន និងគ្មានប្រាក់សងទៅឈ្មោះ [redacted] ANH DUNG ទើបខ្លួនចេញមូលប្បទានបត្រដែលគ្មានសាច់ប្រាក់ឱ្យទៅឈ្មោះ [redacted] ANH DUNG មូលប្បទានបត្រនោះមានទឹកប្រាក់ចំនួន ៣.៣០០.០០០ (បីលាន បីសែន) ដុល្លារអាមេរិក។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណារិទ្ធ បានឆ្លើយថា កាលពីឆ្នាំ២០១០ ឈ្មោះ [redacted] ចាន់នី បានលួងលោមឱ្យខ្លួនបើកក្រុមហ៊ុន [redacted] ណារិទ្ធ អេហ្គ្រីខលឈើរ៍ឡុបមែន ដោយឱ្យខ្លួនឈរឈ្មោះជាប្រធានក្រុមហ៊ុននិងឈ្មោះ [redacted] ចាន់នី ជាប្រធានទីផ្សារ គោលបំណងរបស់គាត់ដើម្បីធ្វើសកម្មភាពដេញយកព្រៃសម្បទានសេដ្ឋកិច្ច ដោយគាត់បញ្ជាក់ថា ពីមុនគាត់មានក្រុមហ៊ុន ខាំគ្រេត អ៊ិចស៊ីម តែក្រុមហ៊ុននេះមិនអាចដំណើរការបានទេ ហើយមូលហេតុចម្បងដែលខ្លួនព្រមឈរឈ្មោះជាប្រធានក្រុមហ៊ុនដោយសារឈ្មោះ [redacted] ចាន់នី បញ្ជាក់ថាគាត់រត់ការដេញថ្លៃយកដីសម្បទានជិតបានជាស្ថាពរហើយ បើបើកក្រុមហ៊ុនថ្មីមិនទាន់នឹងបាត់បង់ឱកាសទាំងស្រុង ម្យ៉ាងទៀតឈ្មោះ [redacted] ចាន់នី បានជំពាក់ប្រាក់ខ្លួនចំនួន ៤៤៧.០០០ (បួនសែន បួនម៉ឺន ប្រាំពីរពាន់) ដុល្លារអាមេរិក ហើយឈ្មោះ [redacted] ចាន់នី គាត់សន្យាថាពេលគាត់ដេញថ្លៃយកដីព្រៃសម្បទានបាន គាត់មានលទ្ធភាពគ្រប់គ្រាន់អាចសងបំណុលខ្លួន ទើបខ្លួនឈរឈ្មោះឱ្យ តែខ្លួនមិនបានធ្វើសកម្មភាពជាមួយឈ្មោះ [redacted] ចាន់នី សូម្បីតែឈ្មោះ [redacted] ANH DUNG ក៏ខ្លួនពុំស្គាល់ដែរ។

-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ANH DUNG បានឆ្លើយថា កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ ឈ្មោះ [redacted] YOUNG បានណែនាំខ្លួនឱ្យមកភ្នំពេញ ដើម្បីទំនាក់ទំនងជាមួយក្រុមហ៊ុន អៀ ណារិទ្ធ អេហ្គ្រីខលឈើរ៍ឡុបមែន ដើម្បីពិភាក្សារកស៊ីទិញឈើស្របច្បាប់នាំចេញពីកម្ពុជាទៅវៀតណាម បន្ទាប់ពីពិភាក្សាគ្នារួចឈ្មោះ [redacted] ចាន់នី ឈ្មោះ [redacted] YOUNG និងឈ្មោះ [redacted] ណារិទ្ធ បានឃុបឃិតគ្នាប្រើល្បិចយកប្រាក់ពីខ្លួនអស់ចំនួន ២៥០.០០០ (ពីសែន ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយអះអាងថាយកប្រាក់នោះទៅរត់ការច្បាប់វិនិយោគព្រៃគប់ ទំហំ ៥.០០០ ហិចតា នៅខេត្តមណ្ឌលគិរី ហើយឈ្មោះ [redacted] ចាន់នី បានចេញមូលប្បទានបត្រគ្មានសាច់ប្រាក់ មានទឹកប្រាក់ចំនួន ៣.៣០០.០០០

ដុល្លារអាមេរិក ដាក់តម្កល់ ប៉ុន្តែនៅក្នុងអំឡុងពេលនោះឈ្មោះ [redacted] ចាន់នី ឈ្មោះ [redacted] YOUNG និង ឈ្មោះ [redacted] ណារិទ្ធ មិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាទេ។

ក្នុងរឿងនេះខ្លួនប្តឹងទាមទារសំណងការខូចខាតជាប្រាក់ចំនួន ២៥០.០០០ ដុល្លារអាមេរិក និង ទាមទារសំណងជម្ងឺចិត្តចំនួន ៥០.០០០ ដុល្លារអាមេរិក។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយជនរងគ្រោះ និងភស្តុតាងឯកសារនានាពាក់ព័ន្ធក្នុងសំណុំរឿង ឃើញថាជនជាប់ចោទឈ្មោះ [redacted] ចាន់នី ពិតជាបានប្រព្រឹត្តបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ ជនជាប់ចោទឈ្មោះ [redacted] YOUNG និងជនជាប់ចោទឈ្មោះ [redacted]ណារិទ្ធ ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១។

ហេតុនេះសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

លោកមេធាវី [redacted] មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]ណារិទ្ធ បានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ជាក់ស្តែងសកម្មភាពនានាគឺជនរងគ្រោះបានធ្វើផ្ទាល់ជាមួយឈ្មោះ [redacted] ចាន់នី និងឈ្មោះ [redacted]YOUNG ហើយចំណុចនេះឈ្មោះ [redacted] ចាន់នី បានឆ្លើយបញ្ជាក់យ៉ាងច្បាស់លាស់រួចហើយ ម្យ៉ាងទៀតឃើញថាបើឈ្មោះ [redacted]ណារិទ្ធ បានធ្វើសកម្មភាពនិងទទួលផលប្រយោជន៍ពីអំពើនេះមែន ឈ្មោះ [redacted] ចាន់នី គាត់មិនអាចទទួលយកតែម្នាក់បានទេ ជាក់ស្តែងក្រោយពីទទួលប្រាក់ពីជនរងគ្រោះឈ្មោះ [redacted] ចាន់នី បានចេញមូលប្បទានបត្រមានទឹកប្រាក់ចំនួន ៣.៣០០.០០០ ដុល្លារអាមេរិក ដាក់តម្កល់ឱ្យជនរងគ្រោះ ដូចនេះឃើញថាឈ្មោះ [redacted]ណារិទ្ធ ពុំមានជាប់កាតព្វកិច្ចណាមួយជាមួយជនរងគ្រោះទេ។

ហេតុនេះសូមតុលាការសម្រេចឱ្យឈ្មោះ [redacted]ណារិទ្ធ រួចផុតពីបទចោទ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ចាន់នី បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted] ANH DUNG បានឆ្លើយថា កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ ឈ្មោះ [redacted] YOUNG បានណែនាំខ្លួនឱ្យមកភ្នំពេញ ដើម្បីទំនាក់ទំនងជាមួយក្រុមហ៊ុន [redacted]ណារិទ្ធ អេហ្គ្រីខលឈឺវឺឡុបមែន ដើម្បីពិភាក្សារកស៊ីទិញឈើស្របច្បាប់នាំចេញពីកម្ពុជា ទៅវៀតណាម បន្ទាប់ពីពិភាក្សាគ្នារួចឈ្មោះ[redacted] ចាន់នី ឈ្មោះ [redacted]YOUNG និងឈ្មោះ [redacted]ណារិទ្ធ បានឃុបឃិតគ្នាប្រើល្បិចយកប្រាក់ពីខ្លួនអស់ចំនួន ២៥០.០០០ (ពីរសែន ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយអះអាងថាយកប្រាក់នោះទៅរត់ការច្បាប់វិនិយោគព្រៃគប់ទំហំ ៥.០០០ ហិចតា នៅខេត្តមណ្ឌលគិរី ហើយឈ្មោះ[redacted] ចាន់នី បានចេញមូលប្បទានបត្រគ្មានសាច់ប្រាក់ មានទឹកប្រាក់ចំនួន ៣.៣០០.០០០ ដុល្លារអាមេរិក ដាក់តម្កល់ ប៉ុន្តែនៅក្នុងអំឡុងពេលនោះឈ្មោះ [redacted]ចាន់នី ឈ្មោះ [redacted] YOUNG និងឈ្មោះ [redacted]ណារិទ្ធ មិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាទេ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] ចាន់នី បានឆ្លើយថា ខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់មែន ខ្លួននិងឈ្មោះ[redacted]ណារិទ្ធ បានបើកក្រុមហ៊ុន [redacted]ណារិទ្ធ គោលបំណងដើម្បីធ្វើសកម្មភាពចូលដេញថ្លៃព្រៃសម្បទាន បន្ទាប់មកខ្លួននិងឈ្មោះ [redacted] YOUNG បានទំនាក់ទំនងជាមួយឈ្មោះ [redacted]ANH DUNG ដើម្បីឱ្យឈ្មោះ [redacted] ANH DUNG ទម្លាក់ប្រាក់ឱ្យដើម្បីយកប្រាក់នោះទៅចំណាយសិក្សាដីព្រៃ និងដើម្បីប្រមូលឈើលក់ឱ្យឈ្មោះ [redacted] ANH DUNG វិញ ហើយខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted]ANH DUNG ផ្ទាល់ខ្លះនិងខ្លះទៀតទទួលយកបន្តពីឈ្មោះ [redacted] YOUNG ដែលមានចំនួនសរុបត្រឹមតែ ១០០.០០០ (មួយសែន) ដុល្លារអាមេរិក ប៉ុណ្ណោះ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ណារិទ្ធ បានឆ្លើយថា កាលពីឆ្នាំ២០១០ ឈ្មោះ[redacted] ចាន់នី បានលួងលោមឱ្យខ្លួនបើកក្រុម [redacted] ណារិទ្ធ អេហ្គ្រីខលឈឺវឺឡុបមែន ដោយឱ្យខ្លួនឈរឈ្មោះជាប្រធានក្រុមហ៊ុន និងឈ្មោះ [redacted] ចាន់នី ជាប្រធានទីផ្សារ គោលបំណងរបស់គាត់ដើម្បីធ្វើសកម្មភាពដេញយកព្រៃសម្បទានសេដ្ឋកិច្ច ដោយគាត់បញ្ជាក់ថាពីមុនគាត់មានក្រុមហ៊ុនឈ្មោះ ខាំត្រេត អ៊ិចស៊ីម តែក្រុមហ៊ុននេះមិនអាចដំណើរការបានទេ ហើយមូលហេតុចម្បងដែលខ្លួនព្រមឈរឈ្មោះជាប្រធានក្រុមហ៊ុន ដោយសារឈ្មោះ [redacted]ចាន់នី បញ្ជាក់ថាគាត់រត់ការដេញថ្លៃយកដីសម្បទានជិតបានជាស្ថាពរហើយ បើបើកក្រុមហ៊ុនថ្មីមិនទាន់នឹងបាត់បង់ឱកាសទាំងស្រុង ម្យ៉ាងទៀតឈ្មោះ[redacted] ចាន់នី បានជំពាក់ប្រាក់ខ្លួនចំនួន ៤៤៧.០០០ (បួនសែន បួនម៉ឺន ប្រាំពីរពាន់) ដុល្លារអាមេរិក ហើយឈ្មោះ [redacted] ចាន់នី គាត់សន្យាថាពេលគាត់ដេញថ្លៃយកដីព្រៃសម្បទានបាន គាត់មានលទ្ធភាពគ្រប់គ្រាន់អាចសងបំណុលខ្លួនទើបខ្លួនឈរឈ្មោះឱ្យ តែខ្លួនមិនបានធ្វើសកម្មភាពជាមួយឈ្មោះ [redacted]ចាន់នី សូម្បីតែឈ្មោះ [redacted]ANH DUNG ក៏ខ្លួនពុំស្គាល់ដែរ។

៤-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយជនរងគ្រោះបញ្ជាក់បានថា ឈ្មោះ[redacted]ចាន់នី

Scanned with CamScanner

មានចេតនាទុច្ចរិតជាមុនសកម្មភាពនេះផ្តើមឡើងដោយការរៀបចំល្បួងលោមឱ្យឈ្មោះ [redacted] ណារិទ្ធ បើកក្រុមហ៊ុន [redacted] ណារិទ្ធ អេហ្គ្រីខលឈ័រឌីវ៉ឡុបម៉ែន មានទីតាំងនៅអាសយដ្ឋានរបស់ឈ្មោះ [redacted] ណារិទ្ធ បន្ទាប់ មកឈ្មោះ [redacted] ចាន់នី បានឱ្យបក្ខពួកខ្លួនឈ្មោះ [redacted] YOUNG អូសទាញជនរងគ្រោះឱ្យមកស្គាល់ ទីតាំងក្រុមហ៊ុន [redacted] ណារិទ្ធ អេហ្គ្រីខលឈ័រឌីវ៉ឡុបម៉ែន និងបានធ្វើសកម្មភាពអូសទាញឱ្យជនរងគ្រោះប្រគល់ប្រាក់ឱ្យតាមរយៈអះអាងថា ក្រុមហ៊ុនរបស់ខ្លួនទទួលបានសិទ្ធិដីសម្បទាន និងប្រមូលផលព្រៃឈើលក់ឱ្យជនរងគ្រោះវិញ។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នី និងឈ្មោះ [redacted] YOUNG ដែលបានប្រើឧបាយកលទុច្ចរិត អូសទាញជនរងគ្រោះ ឱ្យជនរងគ្រោះជឿតាមរហូតបានធ្វើខូចប្រយោជន៍ដល់ជនរងគ្រោះ តាមរយៈអំពើនេះមានធាតុផ្សំគ្រប់គ្រាន់ជាបទ ឆបោក ដូចបញ្ញត្តិតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៦-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នី បានឆ្លើយថា ខ្លួនបានប្រគល់មូលប្បទានបត្រគ្មានសាច់ប្រាក់ឱ្យទៅជនរងគ្រោះ ចម្លើយនេះស្របទៅនឹងភស្តុតាង មូលប្បទានបត្រលេខ ០៤៩១២២ របស់ធនាគារ វឌ្ឍនៈ មានទឹកប្រាក់ចំនួន ៣.៣០០.០០០ (បីលាន បីសែន) ដុល្លារអាមេរិក ដូចនេះកំណត់បានថា ជនជាប់ចោទបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នី ដែលបានចេញមូលប្បទានបត្រប្រគល់ឱ្យជនរងគ្រោះខណៈដែលដឹងជាមុនថា ពុំមានសាច់ប្រាក់ក្នុងគណនី តែបានចេញឱ្យជនរងគ្រោះ បញ្ជាក់បានថា ជនជាប់ចោទមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនេះ ការមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាននៅពេលឥណប្រតិទាន ដោយមានបំណងនិងមានចេតនាធ្វើឱ្យខូចប្រយោជន៍ជនរងគ្រោះ មានធាតុផ្សំគ្រប់គ្រាន់ជាបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

៨-ជនជាប់ចោទឈ្មោះ [redacted] ចាន់នី និងឈ្មោះ [redacted] YOUNG ជានីតិជន និងជាជនមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

៩-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និងមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នី ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ និងជនជាប់ចោទ [redacted] YOUNG និងពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១។

១០-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី

Scanned with CamScanner

ភ្នំពេញ បានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ចាន់នី ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ដោយកំណត់កាលបរិច្ឆេទ នៃការប្រព្រឹត្តបទល្មើសនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ ប៉ុន្តែតាមរយៈមូលប្បទានបត្រលេខ ០៤៩១២២ របស់ធនាគារ វឌ្ឍនៈ មានទឹកប្រាក់ចំនួន ៣.៣០០.០០០ (បីលានបីសែន) ដុល្លារអាមេរិក ដែលជនជាប់ចោទបានផ្តល់ឱ្យជនរងគ្រោះ ចុះកាលបរិច្ឆេទនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ ដូចនេះគប្បីកែប្រែកាលបរិច្ឆេទនៃបទល្មើសនេះវិញ។

១១-តាមចម្លើយជនជាប់ចោទរបស់ឈ្មោះ [redacted] ណារិទ្ធ បានឆ្លើយថា ខ្លួនមិនបានធ្វើសកម្មភាពអូសទាញជនរងគ្រោះ ដើម្បីឱ្យជនរងគ្រោះផ្តល់ប្រាក់ ឬអត្ថប្រយោជន៍ដល់ខ្លួនទេ ចម្លើយនេះស្របទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នី ដូចនេះកំណត់បានថា ជនជាប់ចោទពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

១២-ពុំមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ណារិទ្ធ ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១។

១៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នី បានឆ្លើយទទួលស្គាល់ថា ខ្លួនបានទទួលប្រាក់ពីជនរងគ្រោះបានចំនួន ១០០.០០០ ដុល្លារអាមេរិក ប៉ុន្តែជនរងគ្រោះបានបញ្ជាក់ថា បានប្រគល់ឱ្យចំនួន ២៥០.០០០ ដុល្លារអាមេរិក ហើយជនរងគ្រោះបានប្តឹងទាមទារសំណងចំនួន ២៥០.០០០ ដុល្លារអាមេរិក ការទាមទារនេះមានមូលហេតុសមស្រប ដោយសារជនជាប់ចោទឈ្មោះ [redacted] ចាន់នី បានចេញមូលប្បទានបត្រឱ្យទៅជនរងគ្រោះមានទឹកប្រាក់ចំនួន ៣.៣០០.០០០ ដុល្លារអាមេរិក តែជនរងគ្រោះមិនបានទាមទារសំណងតាមទំហំ នៃទឹកប្រាក់ក្នុងមូលប្បទានបត្រនោះទេ ដូចនេះគប្បីទទួលស្គាល់ការទាមទាររបស់ជនរងគ្រោះ។

១៤-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចាន់នី ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ និងពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ និងជនជាប់ចោទឈ្មោះ [redacted] YOUNG ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១។

## ហេតុដូច្នេះសម្រេច

១/-ឱ្យឈ្មោះ [redacted] ណារិទ្ធ ហៅ គោរព ភេទប្រុស អាយុ ៥០ ឆ្នាំ រួចផុតពីបទចោទ ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវ

Scanned with CamScanner

លេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១។

២/-ផ្តន្ទាទោស៖

ក/-ឈ្មោះ [redacted] ចាន់ធី ភេទប្រុស អាយុ ៥៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ។

ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹង កេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ និងពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣។

ខ/-ឈ្មោះ [redacted] YOUNG ភេទប្រុស អាយុ ៥០ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ។

ពីបទ ឆបោក តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅផ្ទះលេខ២៣៩E0 ផ្លូវលេខ៣០៦ សង្កាត់បឹង កេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១។

៣/-ឱ្យឈ្មោះ [redacted] ចាន់ធី និងឈ្មោះ [redacted] YOUNG រួមគ្នាសងសំណងរដ្ឋប្បវេណី ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ANH DUNG ចំនួន ២៥០.០០០ (ពីរសែនប្រាំម៉ឺន) ដុល្លារអាមេរិក ការទាមទារលើសពីនេះច្រានចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ឈ្មោះ [redacted] ចាន់ធី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ណារិទ្ធ ហៅ គោរព និងឈ្មោះ [redacted] YOUNG និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ANH DUNG ប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។

-គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០
ក្រឡាបញ្ជី

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner